មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0106

# សម្ភាសន៍ជាមួយ វី ឈួន ភេទប្រុស អាយុ៥៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័ត

## សព្វថ្ងៃរស់នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ជា ផល្លា

## ០០:៥២:២៦ និង ០០:១៥:២៦

## ៣០ទំព័រ

ផល្លាៈ អញ្ចឹងលោកពូខ្ញុំសូមចាប់ផ្តើមលោកពូឈ្មោះអីដែរ?

ឈួនៈ ខ្ញុំឈ្មោះវី ឈួន ។

ផល្លាៈ វី ឈួន?

ឈួនៈ បាទ!

ផល្លាៈ ពូអាយុប៉ុន្មានដែរឥលូវ?

ឈួនៈ អាយុ៥៥ឆ្នាំ ។

ផល្លាៈ ពូឥលូវមានតួនាទីជាអីដែរ?

ឈួនៈ មេភូមិ ។

ផល្លាៈ ជាមេភូមិនៅភូមិអីដែរលោកពូ?

ឈួនៈ នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ។

ផល្លាៈ ពូអាចជួយរៀបពីតំបន់ហ្នឹងដូចថាពីមុនជំនាន់ខ្មែរក្រហមតិចតួច ពេលក្រោយម៉ោនៅជំនាន់ហ្នឹងបន្ទាប់ម៉ោបន្តមកដល់ឥលូវហ្នឹងវាម៉េចដែរនៅក្នុងភូមិ ហើយជីវភាពរស់នៅ និងប្រវត្តិរបស់លោកពូផ្ទាល់អីចឹងធ្លាប់ជួបប្រទះអីខ្លះ ចាំ! ពូជួយរៀបរាប់តាំងពីដំបូងដើមឡើយ ។

ឈួនៈ កាលពីសម័យរាជនិយមរហូតដល់សម័យប៉ុច្ចុប្បន្ននេះហ្នឹងដូចខ្ញុំនៅសម័យសាធារណៈហើយនៅសម័យសាធារណៈខ្ញុំរៀន ខ្ញុំកំពុងតែរៀនពេលនោះស្រាប់តែមានសង្គ្រាមកើតឡើង ដល់ចឹងការរៀនសូត្រហ្នឹងបានតិចតួចស្តួចស្តើង ហើយការលំបាកនៅក្នុងសម័យសង្គ្រាមហ្នឹងវាមានការលំបាកណាស់នៅតំបន់នេះ ។

ផល្លាៈ អញ្ចឹងលោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ឈួនៈ ខ្ញុំមានបងប្អូនដល់ទៅ៨នាក់ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ផល្លា៖ បងប្អូន៨នាក់?

ឈួន៖ បាទ!

ផល្លា៖ អញ្ចឹងកាលហ្នឹងឪពុកម្ដាយពូរកស៊ីអីដែរ?

ឈួន៖ ឪពុកម្ដាយខ្ញុំធ្វើស្រែធ្វើចំការ ។

ផល្លា៖ នៅស្រុកហ្នឹងដែរលោកពូ?

ឈួន៖ បាទ!

ផល្លា៖ នៅស្រុកថ្មពួក?

ឈួន៖ នៅភូមិស្វាយ!

ផល្លា៖ ចាំ!ភូមិស្វាយ ឃុំថ្មពួក?

ឈួន៖ បាទ!

ផល្លា៖ អញ្ចឹងលោកពូជាកូនទីប៉ុន្មានដែរ?

ឈួន៖ ខ្ញុំជាកូនទី៤!

ផល្លា៖ កូនទី៤?

ឈួន៖ បាទ!

ផល្លា៖ អញ្ចឹងកាលជំនាន់ហ្នឹងលោកពូរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ឈួន៖ កាលហ្នឹងរៀនបានត្រឹមថ្នាក់ទី៦ កាលហ្នឹងសម័យរំដោះខ្ញុំរៀនបាន២ខែ ។

ផល្លា៖ ថ្នាក់ទី៦នៅសាលាណាលោកពូ?

ឈួន៖ សាលាអនុវិទ្យាល័យថ្មពួក ។

ផល្លា៖ ចុះស្ថានភាពនៅក្នុងភូមិយ៉ាងម៉េចដែរលោកពូពេលមុនខ្មែរក្រហម មានជ្រួលច្របល់អីទេ?

ឈួន៖ ច្របូកច្របល់! ពីសម័យនោះគឺមុនខ្មែរក្រហមនោះគឺច្របូកច្របល់ណាស់ ដោយសារថាដូចខ្លាចសង្គ្រាម ថាអ៊ំយាកកុងយាកមីងណាម៉ោសម្លាប់អីណីងណ៎ា គឺមានការភិតភ័យផ្អើលទៅដល់ពេលនេះទៅបងប្អូនដូចជាមិនសូវប្រកបការងារអីទេដោយសារមានការភិតភ័យខ្លាចសង្គ្រាម ព្រោះពីដើមម៉ោពូដែរ ពុថាសង្គ្រាមៗប៉ុន្តែមិនដែលបានជួបប្រទះ ដល់ក្រោយម៉ោពុចឹងទៅបងប្អូនអត់មានកំលាំងកាយកំលាំងចិត្តធ្វើអីទេ ដល់ជួបការលំបាកជាច្រើនក្នុងបញ្ហា....ៗៗ

ផល្លា៖ ពូថាមានយាកកុងមានអីហ្នឹងមានមែនអត់ពូ ភូមិហ្នឹង?

ឈួន៖ អត់មានទេ! គេគ្រាន់តែថាឃោសនាហ្នឹង ។

ផល្លា៖ ពីណាគេជាអ្នកឃោសនា?

ឈួន៖ ពួកខ្មែរក្រហម ។

ផល្លា៖ អញ្ចឹងបានន័យថាពួកខ្មែរក្រហមមកដល់ស្រុកភូមិហ្នឹងតាំងពីឆ្នាំប៉ុន្មានទៅ?

ឈួន៖ ឆ្នាំ១៩៧៥ ។

ផល្លា៖ ៧៥? ចុះមុន៧៥ហ្នឹងមានអីខ្លះអត់លោកពូ? ស្ថានភាពអី?

ឈួន៖ មុន៧៥គឺខ្មែរសេរី គឺខាងខ្មែរសេរីហ្នឹងវាធ្វើបាបនៅសម័យនោះឯង សម័យសាធារណៈ ។

ផល្លា៖ ខ្មែរសេរីហ្នឹងតាំងពីឆ្នាំប៉ុន្មានដែរលោកពូ? អញ្ចឹងលោកពូកាលជំនាន់លន់ នល់ហ្នឹងនៅក្នុងភូមិហ្នឹងដូចថាមានចលនាអីខ្លះមើលទៅ?

ឈួន៖ បាទ! មានចលនាដូចខ្ញុំបាននិយាយហើយថាវាឃោសនាលិចកើតហ្នឹង ឃោសនាថាយាកគុង យាកមីងហ្នឹងមកសម្លាប់អញ្ចេះអញ្ចុះ យកក្បាលខ្មែរតែឮខាងនោះទេ វាអត់ទាន់ចូលម៉ោទេ! វាគ្រាន់តែឃោសនាឲ្យខ្មែរមួយចំនួនហ្នឹងចូលព្រៃតស៊ូ ដល់ចឹងទៅអាខ្មែរយើងដែលនៅហ្នឹងអត់មានកម្លាំងកាយកម្លាំងចិត្តនឹងប្រកបមុខរបរអីទេ មិនតែប៉ុណ្ណោះថែមទាំងមានចោរ ចោរលួចគោ លួចក្របីរបស់បងប្អូនដែលទៅព្រៃឆ្ងាយៗ ដូច្នេះបណ្តាលឲ្យបងប្អូនហ្នឹងអត់មានទៅធ្វើការឬក៏ទៅធ្វើស្រែនៅឆ្ងាយៗឬក៏បរទេសកាត់ព្រៃអីបានទេ វាលួច ។

ផល្លា៖ ចោរហ្នឹងម៉ោពីណាដែរ?

ឈួន៖ ចោរហ្នឹងមិនដឹងម៉ោពីណាពីណី ពីស្រុកណាពីស្រុកណីទេ ឃើញតែលួចហើយក៏បាត់ដំណឹងជ្រាបមិនដឹងទៅណា ។

ផល្លា៖ អញ្ចឹងលោកពូអត់មានសង្ស័យថាជាខ្មែរក្រហមជាអីទេចោរហ្នឹង?

ឈួន៖ មិនដឹងជាម៉ោពីណាពីណី លួចបាត់មិនដែលតាមដានដឹងទេ បាទដូច្នេះបងប្អូនមួយចំនួនមានការសុទ្ធកម្មយ៉ាងខ្លាំងបញ្ហាពីសម័យនោះ វេទនាណាស់នៅតំបន់នេះ ហើយដល់ពេលសម័យខ្មែរក្រហមចូលនៅឆ្នាំ១៩៧៥ម៉ោនៅតំបន់នេះគឺពួកខ្មែរក្រហមវាចូលឃោសនាថា«ខ្មែរក្រហមឃោសនាមិនឲ្យខ្មែររត់ទៅថៃទេដោយសារចង្អៀតអស់ហើយ ហើយទ័ពនៅតំបន់នេះដូចស្រម៉ោចអញ្ចឹងមិនអាចទៅបានទេ ដូច្នេះវាប្រើឲ្យបងប្អូនប្រជាពលរដ្ឋការមួយគ្រួសារ៤០ ៥០ដើម្បីយកទៅដាក់នៅទីនោះរហូតដល់មានទាំងគុកទាំងរបង ។

ផល្លា៖ ធ្វើដាក់នៅកន្លែងណាលោកពូ?

ឈួន៖ នៅកន្លែងព្រំទ័ណ្ឌ ។

ផល្លា៖ ព្រំដែនកម្ពុជាថៃ?

ឈួនៈ ហ្នឹងអើយ!

ផល្លាៈ គ្រាន់តែចូលម៉ោភ្លាមខ្មែរក្រហមប្រកាសភ្លាមប្ក៏ម៉េច?

ឈួនៈ យើងគ្រាន់ធ្វើគ្រាប់ តែបើយើងមិនធ្វើគ្រាប់តាមទេគឺត្រូវស្លាប់ អ្នកណាហ៊ានជំទាស់គឺត្រូវស្លាប់ ដល់អញ្ចឹងទៅបងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវតែធ្វើតាមទាំងអស់អត់មានអ្នកណាហ៊ានប្រកែកទេ គេនិយាយថាដាំដែកគោលនៅលើក្បាលមិនឲ្យនិយាយហើយមិនឲ្យតវ៉ាទេ គ្មានសិទ្ធតវ៉ាទេ ។

ផល្លាៈ អញ្ចឹងខ្មែរក្រហមមានជម្លៀសលោកពូទៅណាទេនៅក្នុងជំនាន់ហ្នឹង?

ឈួនៈ ខ្ញុំអត់បានជម្លៀសទៅណាទេ គ្រាន់តែជាកងចល័តដើរធ្វើការប្រូតកាត់នៅតាមភូមិនា ៗ ។

ផល្លាៈ អញ្ចឹងបានន័យថាអ្នកដែលរស់នៅក្នុងភូមិហ្នឹងអត់មានគេជម្លៀសទៅណាទេ?

ឈួនៈ មានប្រជាពលរដ្ឋគេជម្លៀសច្រើនណាស់ប្រហែលជា៤០គ្រួសារបានស្លាប់ទាំងអស់គ្មានសេសសល់ទេ ។

ផល្លាៈ ៤០គ្រួសារហ្នឹងគេជម្លៀសទៅណាដែរលោកពូ?

ឈួនៈ គេជម្លៀសទៅសម្លាប់ចោលនៅថ្មពួក គេយកទៅវ៉ៃចោល ជម្លៀសមានពីរវគ្គ វគ្គមួយមុនដំបូងឲ្យទៅដាំកប្បាសនៅភូមិជញ្ជាំង ។

ផល្លាៈ នៅទីណាដែរលោកពូភ្នំហ្នឹង?

ឈួនៈ ភ្នំជញ្ជាំងស្វាយហ្នឹង!

ផល្លាៈ នៅស្វាយ?

ឈួនៈ បាទ! ហើយក្រោយមកទៀតទៅអាជម្លៀសហ្នឹងក៏ត្រលប់មកវិញ ហើយលើកទីពីរគេឲ្យទៅទៀត ដល់ទៅទៀតអត់បានទៅដល់ទេ ជួបជុំនៅចំនុចថ្មពួកហ្នឹងស្លាប់អស់អាលីង ។

ផល្លាៈ លើកទីមួយនៅឆ្នាំប៉ុន្មានដែរលោកពូ?

ឈួនៈ ឆ្នាំ៧៨,៧៩ហ្នឹងអើយ!

ផល្លាៈ ហេតុអីបានជាគេជម្លៀសទៅខាងហ្នឹងវិញលោកពូ កាលឆ្នាំ៧៦,៧៧ហ្នឹង?

ឈួនៈ គោលបំណងគេចង់សម្លាប់ខ្មែរ! ខ្មែរដែលបម្រើយុទ្ធនាការពីរបបមុន ដូចជារបបសាធារណៈរបបអាណាចក្រកម្ពុជា ហើយនឹងរបបដូចជាគ្រូដូចជាអីហ្នឹងគេយកទៅសម្លាប់ចោលទាំងអស់

ផល្លាៈ ចា៎!

ឈួនៈ និយាយទៅអ្នកដែលចេះទាំងប៉ុន្មានគេយកទៅសម្លាប់ចោលទាំងអស់ ទាហ៊ានអ្នកកាន់វ៉ាយកទៅសម្លាប់ចោលទាំងអស់ អត់មានសេសសល់ទេ!

ផល្លា៖ ចុះលោកពូយ៉ាងម៉េចដែរជីវិតលោកពូផ្ទាល់ កាលពេលហ្នឹង?

ឈួន៖ ខ្ញុំដាំដើមគអត់ហ៊ាននិយាយអីទាំងអស់ គេឲ្យធ្វើអីគឺធ្វើហ្នឹងអត់មានប្រកែកទេ ។

ផល្លា៖ កាលហ្នឹងលោកពូអាយុប្រហែលជាប៉ុន្មានដែរ?

ឈួន៖ អាយុ៣០ជាង!

ផល្លា៖ ហ្នឹងអើយប្រហែលជា២០,៣០ហ្នឹង!

ឈួន៖ បាទ! ៣០ជាង!

ផល្លា៖ ចាំ!

ឈួន៖ គេឲ្យខ្ញុំដើរចល័ត ខ្ញុំចេះតែស៊ូទៅ ខ្ញុំលួចយំក្នុងចិត្ត ខ្ញុំនឹកឃើញស្រម៉ៃកាលហ្នឹងគឺស្រក់ទឹកភ្នែក ។

ផល្លា៖ ចាំ!

ឈួន៖ ព្រោះខ្ញុំវេទនាណាស់ គេឲ្យខ្ញុំដើរតាមកងចល័ត ខ្ញុំកាន់បញ្ជីផងខ្ញុំដឹកនឹងគេដែរ! ដូច្នេះវេទនាណាស់តែខ្ញុំមិនហ៊ាននិយាយ គេស្តាប់ចោក៏អត់ហ៊ាននិយាយ ព្រោះការបម្រើយុទ្ធនាការរបស់ គេគឺត្រូវតែធ្វើតាមគេ បើហ៊ានតែជំទាស់ស្លាប់ ។ ខ្ញុំមិននឹកស្មានថាខ្ញុំនឹងបានរស់ ដោយសារ តែខ្ញុំហ្នឹងអត់ធន់តស៊ូទៅខ្ញុំបានរស់មានជីវិតតស៊ូបានខ្ញុំនឹកឃើញសម័យនេះខ្ញុំមានការសង្វេក ខ្លាំងណាស់ ធ្លាប់ជួបការលំបាកអត់បាយមួយថ្ងៃ ពីថ្ងៃបីថ្ងៃខ្ញុំធ្លាប់ហើយ ដោយសារតែអត់បាយឆ្លងកាត់ពីសមរភូមិមួយទៅសមរភូមិមួយវេទនាមែនទែន ព្រោះដើរចល័តពីត្រពាំងថ្មរទៅម្តុំអូតាឡូក ពីភ្នំអូត្រឡូកឬក៏កូនខ្វែងគឺអត់បាយអត់ទឹកមួយអាទិត្យជាងក៏មានដែរ ។

ផល្លា៖ ចល័តហ្នឹងចល័តម៉េចទៅលោកពូ ចល័តគ្រាន់ថាដឹកជញ្ជូនអីឬក៏?

ឈួន៖ ចល័តនេះគឺចល័តទាំងដីក ដីកព្រែក ដីកទំនប់ បិទទំនប់អាងត្រពាំងថ្ម នឹងដីកព្រែកនៅតាប៉ុនហើយដីកព្រែកគឺវេទនាណាស់ ដួកកាលយើងឥលូវនេះយើងកំពុងតែដីកព្រែកចេះ ដកពីព្រែកទៅទំនប់ ហើយដាច់បាយរយៈពេល...ឧទាហរណ៍ថាយើងដើររយៈពេល១០គីឡូចឹងទៅយើងដាច់បាយមួយយប់មួយថ្ងៃ អ្នកខ្លះងាប់តាមផ្លូវក៏មាន អ្នកខ្លះកើតខ្យល់ ហើយកាលដែលចេញពីសមរភូមិមួយខ្លះលីឈើទៅ ទៅដល់យើងរៀបចំខ្លួនយើងអត់មានអ្នកណារៀបចំឲ្យយើងទេ ធ្វើជម្រកខ្លួនយើង តែគេហ្នឹងគេដោះស្រាយតែស្បៀងទេបើមានក៏ហូបបើអត់មានអត់!

ផល្លា៖ ចុះកាលហ្នឹងពីណាជាប្រធានសហករណ៍លោកពូ ឈ្មោះអីដែរ?

ឈួនៈ ប្រធានសហករណ៍ខាងនោះគេខាងស្រុកខាងអ្នកសេដ្ឋកិច្ច ខាងអ្នកគ្រប់គ្រងអ្នកកាន់កាប់សហករណ៍គេត្រូវនៅតាមមូលដ្ឋានគេ ឯកងចល័តគឺនៅតាមកសិដ្ឋានគេអ្នកដោះស្រាយ អភិបាលស្រុកឬក៏ភូមិភាគដែលចូលរួម ។

ផល្លាៈ អញ្ចឹងកាលហ្នឹងពីណាគេជាអ្នកមេកងឬក៏មេក្រុមដែលគ្រប់គ្រងកងលោកពូហ្នឹង?

ឈួនៈ មេកងខ្ញុំនៅភ្នំស្រុកឈ្មោះ...មិនដឹងស្រុកកំណើតនៅណា!

ផល្លាៈ គាត់ឈ្មោះអីដែរលោកពូ?

ឈួនៈ ឈ្មោះ ដាវ!

ផល្លាៈ ឈ្មោះ ដាវ?

ឈួនៈ បាទ!

ផល្លាៈ តួនាទីជាអីដែរលោកពូ?

ឈួនៈ កងចល័ត!

ផល្លាៈ អញ្ចឹងកាលជំនាន់ខ្មែរក្រហមហ្នឹងស្ថានភាពក្នុងភូមិហ្នឹងយ៉ាងម៉េចដែរលោកពូ ទាំងនៅព្រំដែន ទាំងនៅអីលោកពូ?

ឈួនៈ ខាងព្រំដែនហ្នឹងតឹង បើនៅក្នុងភូមិនេះការហូបចុកអត់មានហូបឯកជនទេគឺហូបរួម ពេលដែលទៅហូបគឺកាន់តែស្លាបព្រាមួយនឹងចានមួយសម្រាប់ចែករបប ពេលនោះរបបដែលតឹងតែងគឺរបប១០០នាក់១០កំប៉ុង ហើយការធ្វើគឺមានកំណត់ៗថាពេលព្រឹកនៅម៉ោង៧គឺត្រូវទៅដល់ស្រែ ហើយដល់ម៉ោង១១គឺហូបបបរ ហូបបបររួចទៅគឺសម្រាករហូតដល់ម៉ោង១បានចូលធ្វើ ការ អានេះចំពោះយុវវ័យ ចំពោះវ័យកណ្ដាល ចំពោះខាងយុវជននឹងយុវនារីធ្វើការពីម៉ោង ៧ដែរដល់ម៉ោងដូចគ្នាដែរ ហើយហូបបាយល្ងាចម៉ោង៦ម៉ោង៧ ម៉ោង៧ចាប់ផ្ដើមធ្វើទៀត រហូតដល់ម៉ោង១១បានសម្រាក
ដល់ម៉ោង៤គេក្រោកទាំងអស់គ្នាដើរដាស់បងប្អូនទាំងអស់គ្នា ឲ្យក្រោក ។

ផល្លាៈ អញ្ចឹងកាលហ្នឹងលោកពូគ្រាន់តែនៅកងចល័តអត់មានធ្វើស្រែធ្វើអីណាទេលោកពូ?

ឈួនៈ ធ្វើស្រែ អស់ពីស្រែធ្វើអីផ្សេងៗទៀតចឹងទៅ ។

ផល្លាៈ ចុះនៅហ្នឹងមានគេយកទៅសម្លាប់យកទៅអីទេលោកពូ?

ឈួនៈ យក! អ្នកណាដែលហ៊ានជិតាស់ផាប់ គេថាអង្គការដេញគឺផាប់ដូច្នេះសូម្បីតែនៅក្នុងភូមិរបស់យើងក៏មានផាប់ដែរ ប៉ុន្តែក្នុងនោះដោយសារតែខុសមាត់ខុសសម្ដីហើយក៏គេយកទៅសម្លាប់ទៅ ។

ផល្លាៈ ខុសហ្នឹងខុសម៉េចទៅលោកតា?

ឈួនៈ ដូចថាតាមដាមនិយាយលេងហ្នឹង! និយាយតាមដាមខទាហរណ៍ថាប្រជាពលរដ្ឋហ្នឹងហូបបាយប្រធានសហករណ៍ដល់ចឹងទៅគេយកទៅសម្លាប់ទៅ ។

ផល្លាៈ និយាយហ្នឹងនិយាយពេលក្នុងពេលប្រជុំឬក៏ម៉េច?

ឈួនៈ មិនមែននៅពេលប្រជុំទេ
នៅពេលធ្វើការហោៗ ទៅវាមានអាខាងបងប្អូនមួយចំនួនដែលជាសហការីរបស់ប្រធានសហករណ៍ហ្នឹងរាយការណ៍ទៅ ។

ផល្លាៈ ចុះគាត់ហ្នឹងត្រូវជាស្អីនឹងលោកតាដែរ មានសាច់ញាតិមានអីអត់លោកតា អ្នកដែលត្រូវខ្មែរក្រហមសម្លាប់មានសាច់ញាតិទេ?

ឈួនៈ នៅក្នុងភូមិនេះដែលសាច់ញាតិខ្ញុំអត់មានទេ មានតែគេផ្សេងទេ មានតែអ្នកដទៃ ។

ផល្លាៈ អ្នកដទៃហ្នឹងលោកតាស្គាល់ដែរឬអត់ទេលោកតា?

ឈួនៈ ស្គាល់!

ផល្លាៈ ត្រូវជាមិត្តឬក៏ម៉េចលោកតា?

ឈួនៈ កូនចៅ!

ផល្លាៈ

អញ្ចឹងលោកតាកាលជំនាន់មុនជំនាន់ខ្មែរក្រហមហ្នឹងលោកតាអាយុ២០ជាងហ្នឹងលោកតាធ្វើការអី ដែរលោកតា មានតួនាទីជាអីដែរ?

ឈួនៈ មុនខ្មែរក្រហមហ្នឹង?

ផល្លាៈ មុនខ្មែរក្រហមជំនាន់លន់ នល់ ណាំលោកតាមានតួនាទីជាអីដែរ?

ឈួនៈ អត់មានតួនាទីជាអីទេ ខ្ញុំនៅរៀន!

ផល្លាៈ នៅរៀនធម្មតា?

ឈួនៈ បាទ! នៅរៀនយុវជន ។

ផល្លាៈ ព្រោះមើលទៅអាយុប្រហែលជា២០ជាងហើយលោកតា?

ឈួនៈ អាយុខ្ញុំ២០ជាងហើយ! ព្រោះខ្ញុំរៀនតាំងពីអាយុ១២,១៣ ឪពុកខ្ញុំអាល័យតែឈឺហ្នឹងបាន ខ្ញុំរៀនបានតែប៉ុន្មានឆ្នាំ ចាប់ពីថ្នាក់ទី១២រហូតដល់ថ្នាក់ទី៩ បានប្រហែល៥,៦ឆ្នាំ ។

ផល្លាៈ ចាំ!

ឈួនៈ ដល់ឆ្នាំ៧៥ទៅបានខ្ញុំឈប់រៀន!

ផល្លាៈ នៅហ្នឹងអត់មានបាញ់គ្នាបាញ់អីទេលោកពូពេលមុនពេល៧៥អីហ្នឹង ពេលដែលខ្មែរក្រហម ចូលមកដល់ភូមិ?

ឈួនៈ វៃ៧៥ វៃថ្មពួក!

ផល្លាៈ ខ្មែរក្រហមចូលមកនៅថ្មពួក?

ឈួនៈ បាទ!

ផល្លាៈ ជាមួយទាហ៊ានលន់ នល់មែនពូ?

ឈួនៈ បាទ! ងាប់អស់មិនស្មើរ!

ផល្លាៈ ខាងណា?

ឈួនៈ ទាហ៊ានខ្មែរក្រហម!

ផល្លាៈ ចុះលន់ នល់?

ឈួនៈ អត់អីទេ!

ផល្លាៈ អត់អីដែរ?

ឈួនៈ បាទ! វាងាប់តិចតួច!

ផល្លាៈ ចាំ! អញ្ចឹងអាសាមានវៃគ្នាឬអត់មុនពេលខ្មែរក្រហម....?

ឈួនៈ មានតែនៅព្រៃឯនោះ !

ផល្លាៈ នៅម្តុំណាលោកពូ?

ឈួនៈ ខាងកើតព្រៃនេះ!

ផល្លាៈ ខាងកើតព្រៃ?

ឈួនៈ បាទ!

ផល្លាៈ ព្រៃណាលោកពូ?

ឈួនៈ ព្រៃរបស់ខាងកើតភូមិប្រហែល៤,៥គីឡូ ហើយនៅម្តុំភ្នំព្រះ!

ផល្លាៈ នៅម្តុំភ្នំព្រះ?

ឈ្ងួនៈ បាទទៅវ៉ៃគ្នានៅទីនោះឯង! ប្រាវអញ្ចឹងទៅដកចេញរៀងៗខ្លួនទៅ ខ្លះទៅងាប់ពីបីបួននាក់ទៅ ហើយខាងខ្មែរក្រហមងាប់ច្រើន ។

ផល្លាៈ ខ្មែរក្រហមស្លាប់ច្រើនជាងលន់ នល់ លោកពូ?

ឈ្ងួនៈ បាទ!

ផល្លាៈ អញ្ចឹងកាលជំនាន់ហ្នឹងលន់ នល់ គាត់គ្រប់គ្រងមើលទៅស្រួលតើលោកពូនៅក្នុងតំបន់ណា៎ ពេលខ្មែរក្រហមអត់ទាន់ចូល?

ឈ្ងួនៈ អត់អីដែរ! ប៉ុន្តែវេទនានឹងសម័យ៣ឆ្នាំ ។

ផល្លាៈ ចា៎! ចុះលោកពូនៅហ្នឹងក្រែងឮថាជំនាន់៣ឆ្នាំហ្នឹងមានខាងនារតី ខាងពាយ័ព្យអីគេចូលម៉ោ ម៉េចដែរលោកពូហ្នឹង?

ឈ្ងួនៈ ចំណុចហ្នឹងវាចេះ វាដូរដោះគ្នាដូចថាពួកសហករណ៍ហ្នឹងពួកនារតីចូលម៉ោសម្លាប់ពួកអស់ហ្នឹង ចោល ។

ផល្លាៈ ដំបូងម៉េចទៅពូអាហ្នឹង ម៉េចទៅពួកនារតីចូលម៉ោមុនឬក៏ខាងណាចូលម៉ោមុន?

ឈ្ងួនៈ ពួកសហករណ៍យើងនៅមុន ពួកនារតីគេចូលម៉ោក្រោយ ។

ផល្លាៈ ចា៎!

ឈ្ងួនៈ ចូលម៉ោក្រោយចឹងទៅវាសម្លាប់អានាក់នៅមុនហ្នឹង ។

ផល្លាៈ ដំបូងយើងនៅនេះខាងភូមិភាគពាយ័ព្យមែនលោកពូ?

ឈ្ងួនៈ ភូមិភាគពាយ័ព្យ!

ផល្លាៈ ភូមិភាគពាយ័ព្យហ្នឹងដំបូងពីណាគ្រប់គ្រង?

ឈ្ងួនៈ ខាងភូមិភាគនោះមិនដឹងខាងណាទេខ្ញុំអត់ស្គាល់ផង! ប៉ុន្តែខ្ញុំស្គាល់តែស្រុក ស្រុកឈ្មោះ រស់ ឆាត ។

ផល្លាៈ រស់ ឆាត?

ឈ្ងួនៈ ស្ដី ឆាត ទេអភិបាលស្រុក ។

ផល្លាៈ អភិបាលស្រុក?

ឈ្ងួនៈ បាទ!

ផល្លាៈ គាត់ហ្នឹងម៉េចដែរការគ្រប់គ្រងរបស់គាត់ របៀបថាតឹងរឹង ឬក៏មានសម្លាប់មានអីខ្លាំងអត់ លោកពូ កាលនារតីអត់ទាន់ចូលម៉ោ?

ឈ្ងួនៈ សម្លាប់តែអ្នកណាចបេសទេ!

ផល្លា៖ ហើយចឹងបានន័យថាពេលពួកនារតីចូលម៉ោហ្នឹង ពូមានដឹងថាហេតុអីបានជាពួកនារតីចូលម៉ោដល់ក្នុងភូមិទេ?

ឈួន៖ មិនដឹងដែរ! ស្រាប់តែនារតីចូលម៉ោសម្លាប់ពួកនោះចេញអស់ សម្លាប់មនុស្សរបណ្ដើរៗ អត់ មានអ្នកណាដឹងថាយកទៅសម្លាប់ទេ គ្រាន់តែចូលម៉ោយកទៅរៀនសូត្រ ដល់យកទៅរៀន សូត្រទៅស្រាប់តែសម្លាប់ពួកហ្នឹងចោលអស់ បាត់ខ្លួនអស់មិនដឹងជាយកទៅសម្លាប់នៅឯណា!

ក្រោយម៉ោទៀតពុកតែសម្លាប់ៗ តែមិនដឹងយកទៅសម្លាប់នៅឯណា!

ផល្លា៖ អ៊ំ! អញ្ចឹងពេលដែលនារតីចូលម៉ោហ្នឹងមានប្រធានភូមិដូរអីអត់ទេនៅក្នុងសហករណ៍ ឬក៏អត់មានទេ?

ឈួន៖ ប្រធានភូមិអត់ដូរទេ! ប្រធានអត់មានអីទេ ច្រើនសម្លាប់តែអ្នកផ្សេងទេ ដូចជាកងចល័តធំៗ កន្លែងកសិដ្ឋានធំៗដូចកន្លែងត្រពាំងថ្ម បើនៅក្នុងភូមិអត់អីទេគ្រាន់តែបើធ្វើខុសគេសម្លាប់ដកចេញ ភូមិយើងនេះងាប់តិចណាស់ អានាក់មិនដឹងម៉េចទេ មិនដឹងជិតាស់ឬក៏ម៉េចទេខ្ញុំអាល័យ តែដើរចល័តទៅម៉ោវិញងាប់បងប្អូនអស់ សូម្បីតែបងប្អូនខ្ញុំក៏ងាប់ច្រើនដែរ! ហើយដូចអ្នកចេះៗគេយកទៅរៀនសូត្រ ដល់រៀនសូត្រទៅគេមានយកទៅណាគេយកទៅវ៉ៃចោល ។

ផល្លា៖ ចុះពូពេលដែលចល័តហ្នឹងអត់មានជួបបញ្ហាជួបអីទេលោកពូ?

ឈួន៖ បញ្ហាច្រើនណាស់! បញ្ហាត្រង់ថាទីមួយគឺខ្វះបាយ ទីពីរគឺខ្វះទឹក ហើយទីបីគឺកម្លាំងទន់ខ្សោយ ពួកអាដែលគេគ្រប់គ្រង ដែលគេកាន់កាប់វាយកទៅធ្វើបាប វាយកទៅសម្លាប់ ហើយបងប្អូន កងចល័តដែលស៊ីចុកទៅវាទៅជាឈឺ ដល់ឈឺទៅវាយកទៅសម្លាប់ទៅ ថាវាហ្នឹងថាកងចល័ត នោះមិនទាន់ មិនមានការថាតស៊ូឌឹដដែកប្រឆាំង ។

ផល្លា៖ អញ្ចឹងលោកពូពេលហ្នឹងទៅបានធ្វើគេជម្លៀសឲ្យទៅត្រពាំងថ្ម ភ្នំស្រុក តែពីរបីកន្លែងហ្នឹងទេលោកពូ?

ឈួន៖ ហ្នឹងអើយតែពីបីកន្លែងហ្នឹងទេ!

ផល្លា៖ ហើយដល់ពេលនៅក្នុងហ្នឹងក្រោយពួកនារតីចូលម៉ោហ្នឹងម៉េចទៀតទៅពូនៅក្នុងភូមិម្តុំបន្ទាយមានជ័យហ្នឹងនិយាយទៅម៉េចដែរបន្ទាប់ពីពួកនារតីចូលម៉ោដល់?

ឈួន៖ ច្របូលច្របល់ណាស់! ដូចថាបាសបោលមួយប្រាវចឹងទៅណា៎ ហើយក៏រៀបចំទៅ ដល់មានអ្នកដឹកនាំរកបំពាក់បំពនរកអ្នកដឹកនាំទៀតទៅធ្វើការទៀតទៅ ។

ផល្លា៖ ចុះលោកពូកាលហ្នឹងម៉ោមូលដ្ឋានវិញដែរឬអត់ទេលោកពូ?

ឈួនៈ ខ្ញុំម៉ោពីរបីសារដែរ! ដល់ហើយគេបញ្ជូនទៅវិញ ។

ផល្លាៈ ម៉ោហ្នឹងគេបញ្ជូនឬក៏យើងលួចរត់ម៉ោ?

ឈួនៈ គេឲ្យរំសាយ!

ផល្លាៈ ឲ្យរំសាយ?

ឈួនៈ បាទ!

ផល្លាៈ ពេលពួកនារតីចូលម៉ោហ្នឹងមែនលោកពូ?

ឈួនៈ បាទ! គេឲ្យរំសាយ!

ផល្លាៈ រំសាយហ្នឹងរំសាយកងចល័តហ្នឹងលោកពូ?

ឈួនៈ បាទ!

ផល្លាៈ នៅឆ្នាំប៉ុន្មានដែរហ្នឹង?

ឈួនៈ ប្រហែលនៅឆ្នាំ៧៦,៧៧!

ផល្លាៈ ហេតុអីបានជាគេឲ្យរំសាយអញ្ចឹងលោកពូ?

ឈួនៈ ព្រោះអ្នកដឹកនាំមួយចំនួនហ្នឹងគេសម្លាប់ ដល់អត់មានអ្នកដឹកនាំអញ្ចឹងគេរំសាយសិន ហើយស្បៀងអីហ្នឹងអត់មានឲ្យហូបទេ ដល់ចឹងទៅមានអ្នកណាដោះស្រាយគេឲ្យរំសាយសិន ទម្រាំតែគេដោះស្រាយបានគេហៅទៅវិញ ។

ផល្លាៈ

អញ្ចឹងពេលរំសាយហ្នឹងកងពូដែលដឹកទំនប់ដឹកអីហ្នឹងរំសាយទាំងអស់រលីងតែម្តងហើយមកដល់ សហករណ៍វិញ?

ឈួនៈ បាទ! ម៉ោសហករណ៍វិញ!

ផល្លាៈ ដល់ពេលបន្ទាប់ម៉ោម៉េចទៀតទៅលោកពូ?

ឈួនៈ ដល់បន្ទាប់មកទៀត ដល់ពេលរំសាយទៅដល់ពេលមកធ្វើការនៅនេះ ធ្វើការនៅនេះធ្វើស្រែធ្វើអីទៅ កងចល័តយើងក៏ធ្វើនៅនេះធ្វើនៅសហករណ៍យើងនេះ ។

ផល្លាៈ ចាំ!

ឈួនៈ ដល់ធ្វើសហករណ៍នេះរួចរាល់ប្រូតកាត់ធម្មតាទៅ ប្រមូលផលទៅ ដល់តែបានផលគេយកទៅណាណីណោះ យកអស់ទៅមិនដឹងជាដកទៅណាអស់ ។

ផល្លាៈ ចុះបន្ទាប់មកទៀតលោកពូ?

ឈួនៈ ដល់ពេលដែលថាខ្ទះខាតស្បៀងទៅឃើញដឹកម៉ោបន្តិចបន្តួច ថាសុទ្ធតែទៅជូរគ្រាក់ទ័រគ្រាក់អី ណាណីនោះ សុទ្ធតែដូរគ្រឿងចក្រតាមការពិតដូចមិនឃើញមានអី មិនឃើញមានអីចែកជូនប្រជាពលរដ្ឋផង! ដដែលៗ ហើយដល់ចឹងទៅបងប្អូនប្រជាពលរដ្ឋគ្នាក៏មិនហ៊ានថាអីគេថាមិន បានអីក៏ចេះតែធ្វើទៅ អាសម័យ៣ឆ្នាំនោះធ្វើស្រូវកើតទៀត ហើយសូម្បីតែកន្ទេលៗក៏ធ្វើ កើតទាំងអស់ តែអាបាយហ្នឹងស៊ីអត់គ្រប់មិនដឹងជាយកទៅឯណាឯណី អ្នកណាហូបក៏មិនបាន

ផល្លាៈ អញ្ចឹងកាលហ្នឹងពូអត់ដឹងហ្នងថាគេយកទៅណាទៅណីពូអត់ដឹងហ្នង?

ឈួនៈ អត់ដឹង! មិនដឹងគេយកទៅណា! ដឹកទៅប៉ុន្តែមិនដឹងដឹកយកទៅណា!

ផល្លាៈ អញ្ចឹងបានន័យថាពេលពួកនារតីចូលម៉ោហើយអត់មានខាងណាចូលម៉ោទៀតទេលោកពូ? នារតីគ្រប់គ្រងរហូតទាល់តែបែក៧៩?

ឈួនៈ បាទ!

ផល្លាៈ អញ្ចឹងលោកពូនៅកងចល័តរហូតទាល់តែបែក៧៩ហើយម៉េចទៀតលោកពូ?

ឈួនៈ ៧៩ហើយស្រាប់តែ...យើងនៅការដ្ឋានទៅស្រាប់តែយួនចូលម៉ោឆ្នាំ៧៩ បែកពីការដ្ឋានម៉ោចូលនៅផ្ទះហ្នង!

ផល្លាៈ អញ្ចឹងលោកពូម៉ោផ្ទះវិញ?

ឈួនៈ បាទ! ម៉ោផ្ទះវិញ!

ផល្លាៈ អញ្ចឹងអត់មានស្ថានភាពអីទៀតទេលោកពូ អត់មានខាងប៉ាវ៉ាខាងអីទេលោកពូ?

ឈួនៈ សកម្មភាពខាងក្រៅក្រោយម៉ោទៀតខ្ញុំអត់សូវដឹងទេ! ក្រោយមកទៀតពេល៧៩នេះបានគេយកខ្ញុំទៅតែម្តង!

ផល្លាៈ យកលោកពូទៅ?

ឈួនៈ នែ៎យួនចូលម្តង ដល់យួនចូលម្តងចឹងទៅយួនទៅវិញអស់ ខ្ញុំហ្នឹងពួកខ្មែរក្រហមមករកខ្ញុំមករក ដេញចាប់ខ្ញុំដល់ណាដល់ណី ហើយចាប់ខ្ញុំមិនបានទៅដល់នេះទៅខ្ញុំរត់ទៅថៃ។

ផល្លាៈ ម៉េចបានខ្មែរក្រហមចូលមករកដេញចាប់ពូអញ្ចឹងលោកពូ?

ឈួនៈ ព្រោះកងទ័ពខាងយុវជនខ្ញុំជាអ្នកគ្រប់គ្រងទៅគេស្គាល់ខ្ញុំ ។

ផល្លាៈ អ៎លោកពូជាប្រធានយុវជន?

ឈួនៈ បាទ!

ផល្លាៈ គ្រប់គ្រងប៉ុន្មាននាក់ដែរលោកពូ?

ឈួនៈ	ច្រើនណាស់ មួយសហករណ៍តែម្ដង!

ផល្លាៈ	មួយសហករណ៍?

ឈួនៈ	បាទ!

ផល្លាៈ	អញ្ចឹងពេលដែលនារតីចូលម៉ោអត់មានរករឿងលោកពូអីទេ?

ឈួនៈ	រកខ្ញុំដែរតែខ្ញុំអត់ឲ្យជួបមុខផង! ដល់រកខ្ញុំទៅខ្ញុំទៅជួបប៉ាក់ហ្នឹងទៅ! ដល់ទៅជួបទៅខ្ញុំទៅតាមប៉ាក់ទៅ ដល់៧៩ទៅបានខ្ញុំតស៊ូរយៈពេល៨ខែខ្ញុំឡប់ម៉ោវិញ ឡប់ម៉ោនៅផ្ទះវិញ

ផល្លាៈ	ចុះពីណាជាប្រធាននៅខាងនារតីហ្នឹង? គ្រប់គ្រងនៅខាងភូមិភាគនារតីហ្នឹង ពីណាគេជាអ្នកចូលម៉ោក្នុងភូមិ?

ឈួនៈ	ភូមិនារតីហ្នឹងខាងទ័ព! ខាងទ័ពប៉ិណាត!

ផល្លាៈ	ឈ្មោះអីគេដែរលោកពូ?

ឈួនៈ	ស្ដី ណាត! ស្គាល់តែប៉ិណាតៗ!

ផល្លាៈ	ប៉ិណាតហ្នឹងគាត់ចូលម៉ោហើយពូប្រធានយុវជនដែរ?

ឈួនៈ	បាទ!

ផល្លាៈ	គ្រប់គ្រងមួយសហករណ៍ហ្នឹងប្រហែលប៉ុន្មាននាក់ដែរលោកពូ?

ឈួនៈ	គ្រប់គ្រងមួយសហករណ៍ហ្នឹងពីរបីចល័តទេ! តែបើម៉ោតាមភូមិវិញខ្ញុំមិនបានគ្រប់គ្រងទេមានក្រុមគេផ្សេងៗ

ផល្លាៈ	អញ្ចឹងចល័តម្ដងៗពូជាប្រធានយុវជនគ្រប់គ្រងកងចល័តហ្នឹង?

ឈួនៈ	បាទ! គ្រប់គ្រងកងចល័តហ្នឹង!

ផល្លាៈ	មានទាំងស្រីមានទាំងប្រុសលោកពូ?

ឈួនៈ	បាទ! ទាំងស្រីទាំងប្រុសទាំងពីប្រភេទ ក្នុងនោះក៏មានវ័យកណ្ដាលខ្លះជាអ្នកគ្រប់គ្រងដែរៗ

ផល្លាៈ	ចុះមានប៉ុន្មាននាក់នៅក្រោមពូទៀតទេ ពីណាគេនៅគ្រប់គ្រងនៅក្រោមពូដូចប្រធានយុវជនមានពីណានៅក្រោមពូទៀតទេ?

ឈួនៈ	មាន!

ផល្លាៈ	ឈ្មោះអីដែរលោកពូ?

ឈួនៈ	នៅភូមិផ្សេង!

ផល្លាៈ	នៅភូមិផ្សេង?

ឈួនៈ	បាទ!

ផល្លាៈ ចុះពីណាមេពូ?

ឈ្លួនៈ នេះមេខ្ញុំ!

ផល្លាៈ គាត់ឈ្មោះអីគេលោកពូ?

ឈ្លួនៈ ឈ្មោះ ដុះ រាវ!

ផល្លាៈ ដុះ រាវ?

ឈ្លួនៈ បាទ! គាត់ក្តាប់ខាងយុវជន ។

ផល្លាៈ គ្រប់គ្រងខាងយុវជន?

ឈ្លួនៈ បាទ!

ផល្លាៈ តួនាទីគាត់ជាអីគេដែរលោកពូ?

ឈ្លួនៈ ខាងសហករណ៍! សេចកិច្ចនឹងសហករណ៍ ។

ផល្លាៈ សេដ្ឋកិច្ចសហករណ៍ ដល់ពេលលោកពូជាប្រធានយុវជន?

ឈ្លួនៈ បាទ!

ផល្លាៈ ចុះនៅលើគាត់ទៀតមានពីណាទេពូ? គ្រប់គ្រងពីលើគាត់ទៀត?

ឈ្លួនៈ មានខាងស្រុក!

ផល្លាៈ ខាងស្រុក?

ឈ្លួនៈ បាទ!

ផល្លាៈ ឈ្មោះអីដែរ ហើយមានតួនាទីអីដែរ?

ឈ្លួនៈ ឈ្មោះតា តូ!

ផល្លាៈ តា តូ?

ឈ្លួនៈ បាទ!

ផល្លាៈ គាត់ហ្នឹងគ្រប់គ្រងខាងអីដែរលោកពូ?

ឈ្លួនៈ គ្រប់គ្រងខាងកងចល័តស្រុក!

ផល្លាៈ កងចល័តស្រុក?

ឈ្លួនៈ បាទ!

ផល្លាៈ ចុះលើគាត់ទៀតមានពីណាទៀតលោកពូ?

ឈួនៈ	ពីលើគាត់មានភូមិភាគ! កាន់ខាងភូមិភាគហ្នឹងកាន់ពីរបីស្រុកបួនស្រុកនោះ ប៉ុនោះឈ្មោះអីទេ ភ្លេចបាត់ហើយ ប៉ុន្តែវាមិនមែនប្រធានទេគឺនារតីទេប្រធាន អ៉ំឈ្មោះសម្បត្តិប៉ុន្តែមិនដឹងស្អីសម្បត្តិ?

ផល្លាៈ	គាត់សម្បត្តិហ្នឹងជាអីដែរលោកពូ នាទីគាត់?

ឈួនៈ	គួនាទីខាងកាន់បួនស្រុក! ចល័តកាន់បួនស្រុក ។

ផល្លាៈ	កាន់កងចល័តបួនស្រុក?

ឈួនៈ	បួនស្រុក!

ផល្លាៈ	ហើយពូមានខ្លាចគាត់អីអត់ទេ ខ្លាចមេនៅក្នុងជំនាន់ហ្នឹង ដូចថាខ្លាចគេ..?

ឈួនៈ	ខ្លាចណាំ (សើច) ។

ផល្លាៈ	ចុះលោកពូផ្ទាល់មានដែលទៅដូចថាឃើញកូនចៅធ្វើអីខុសអញ្ចឹងហៅទៅរៀនសូត្រហៅប្រដៅអីខ្លះចឹង ដែលអត់លោកពូ? ព្រោះប្រធានយុវជនដែរ!

ឈួនៈ	បាទមានកូនចៅខ្ញុំម្តងវាលួខ្ញុំទៅសុំនារតី ដល់ទៅសុំទៅនារតីថាស្រណោះសមមិត្ត តាំងពីកាន់កងចល័តមិនដែលមានអ្នកណាមកសុំដូចសមមិត្តឯងទេ បានគេអនុញ្ញាតឲ្យ ពីមុនតែចាប់ហើយដឹងតែស្លាប់ហើយ ស្រណោះសមមិត្តឯងខ្ញុំឲ្យសមមិត្តឯងមួយទៅ ខ្ញុំភ្លេចឈ្មោះម្នាក់មួយដែលខ្ញុំបានស្នើរសុំឲ្យរួចខ្លួន ។

ផល្លាៈ	គាត់ហ្នឹងធ្វើអីខុសលោកពូ?

ឈួនៈ	លួចដំឡូងគេ!

ផល្លាៈ	លួចដំឡូង ហើយលោកពូឃើញឬក៏ម៉េចលោកពូ?

ឈួនៈ	បាទខ្ញុំឃើញ ខ្ញុំឃើញទៅខ្ញុំទៅស្នើរសុំវិញ ។

ផល្លាៈ	ឃើញហ្នឹងពីណាគេចាប់ គេចាប់គាត់ឬអត់ទេ?

ឈួនៈ	នារតី!

ផល្លាៈ	នារតីហ្នឹង?

ឈួនៈ	អ្នកភូមិគេនោះគេចាប់បានទៅគេបញ្ជូនម៉ោកងចល័តទៅ នារតីចាប់កឲ្យស្រែកថាបងប្អូនអើយកុំយកតម្រាប់តាមខ្ញុំ ខ្ញុំជាជនល្មើសលួចដំឡូងសមូលហភាពគេ គេដើរស្រែកតាមការដ្ឋាន ។

ផល្លាៈ	ឲ្យគាត់ស្រែក?

ឈួនៈ	បាទ! ឲ្យស្រែក មួយទៅពីនាក់ ចាប់បានបីនាក់ អាមួយដើរស្រែកអាពីរនាក់ទៀតកាន់តុង ។

ផល្លាៈ	អញ្ចឹងលួចដំឡូងហ្នឹងតែម្នាក់ឬក៏បីនាក់លោកពូ?

ឈួនៈ បីនាក់!

ផល្លាៈ បីនាក់?

ឈួនៈ បាទ!

ផល្លាៈ គាត់ឈ្មោះអីខ្លះលោកពូចាំទេ?

ឈួនៈ ភ្លេចឈ្មោះអស់ទៅព្រោះយូណាស់ហើយ ។

ផល្លាៈ ហើយម៉េចបានលោកពូជួយគេអញ្ចឹង?

ឈួនៈ នៅកងជាមួយខ្ញុំ!

ផល្លាៈ អញ្ចឹង?

ឈួនៈ បាទ! ជាកូនចៅខ្ញុំ!

ផល្លាៈ ចុះលោកពូអត់ខ្លាចអីទេលោកពូ?

ឈួនៈ ទេអាខ្លាចនោះវាចេះតែខ្លាចហើយតែយើងតស៊ូដោះស្រាយព្រោះយើងជាអ្នកដឹកនាំគេហើយ យើងត្រូវដោះស្រាយជូនកងចល័ត ហើយបើសិនជាកងចល័តខុសដៃយកដៃ ខុសជើងយកជើងយើងជាមនុស្សធ្វើហើយណា៎ ដូច្នេះបើសិនជាយើងជាមនុស្សធ្វើកូនចៅខុសយើងត្រូវស្នើរសុំគេ ដល់យើងមានធ្វើអីចឹងទៅខាងនោះគេនិយាយថាមិនដែលមានសមមិត្តណាមកសុំដូចសមមិត្តឯងនោះទេ ឥលូវហ្នើយចុះអនុគ្រោះឲ្យសមមិត្តឯងទៅចុះ តែសមមិត្តឯងហ៊ានទទួលខុសត្រូវទេ ខ្ញុំហ៊ានធានាថាវាត្រូវ មានអីជាអាង? ថាវាជាមិត្តខ្ញុំ ដល់អញ្ចឹងទៅនារតីហ្នឹងគេក៏យល់ព្រម បានរស់មកដល់សព្វថ្ងៃហ្នឹង ។

ផល្លាៈ បានរស់បីនាក់ហ្នឹងទៅ?

ឈួនៈ បាទ! ហើយខ្ញុំភ្លេចឈ្មោះវា!

ផល្លាៈ ភ្លេចទាំងពីហ្នឹងហ្មងលោកពូ?

ឈួនៈ បាទភ្លេចទាំងបី! ប៉ុន្តែកូនចៅខ្ញុំតែមួយទេក្រៅពីនោះកូនចៅគេផ្សេង ។

ផល្លាៈ អញ្ចឹងលោកពូគ្រប់គ្រងមួយឃុំថ្នូកតែម្តងលោកពូ?

ឈួនៈ បាទមួយឃុំ!

ផល្លាៈ គ្រប់គ្រងកងចល័តមួយភូមិថ្នូក?

ឈួនៈ បាទ!

ផល្លាៈ អញ្ចឹងលោកពូមានដែល... ចង់និយាយថាមានដែលវៃដែលអីខ្លះអត់ទេ?

ឈួនៈ អត់ទេ!អត់ដែលវៃកងចល័តទេ!

ផល្លា៖ ម៉េចចឹងលោកតូ? ព្រោះដូនកាល...

ឈួន៖ ទេខ្ញុំមិនដែលរើដង! មនុស្សទាំងអស់គ្នាខ្ញុំមិនដែលរើទេ! ខ្ញុំមិនដែលរើរឿងកងចលតអីទេ ខ្ញុំដឹកនាំតាមធម្មតា ក៏ប៉ុន្តែឲ្យស្តាប់គ្នាត្រង់ថាអីដែលកាលៈទេសៈយើងត្រូវធ្វើអីគឺយើងត្រូវធ្វើតែយើងទាំងអស់គ្នាហ្នឹងមិនដឹងជាស្លាប់ថ្ងៃណាទេ ប៉ុន្តែយើងកុំធ្វើបាបគ្នា ហើយយើងរកស៊ីអីក៏រកចុះតែស៊ីហើយកុំឲ្យគេឃើញ តែគេឃើញស្លាប់ ដូនកាលគេយកមេទៅសម្លាប់ក៏មានដែរ ដូនកាលគេយកសមីខ្លួនដែកប្រព្រឹត្តខុសក៏បានដែរ អ៊ីដែលស៊ីចុកដោយសមូលហភាពគឺគេអត់ឲ្យខុសទេ គឺស៊ីដោយសមូលហភាព ស៊ីដោយរួមទាំងអស់អត់មានស៊ីអាវ៉ាត់អារាយទេ យើងគ្រាន់តែថាជាផ្ទៃក្នុងរបស់កងចលត យើងប្រាប់ទៅថាបើស៊ីអីខុសពីសមូលហភាពស៊ីកុំឲ្យអ្នកណាដឹង គេដឹងស្លាប់ ។

ផល្លា៖ ពូប្រាប់ឬក៏គេដឹងគ្រប់គ្នា?

ឈួន៖ ខ្ញុំប្រាប់ គ្រាន់តែប្រាប់ផ្ទៃក្នុងរបស់កូនចៅ ពេលណាដែលគេនៅឆ្ងាយពីយើងណ៎ាយើងប្រាប់កូនចៅរបស់យើងធ្វើម៉េចឲ្យចេះស្គាល់ពីរបៀបរស់យ៉ាងម៉េច របៀបតស៊ូយ៉ាងម៉េច បើយើងខ្វះការតស៊ូហើយមិនប្រុងប្រយ័ត្នយើងស្លាប់ គេឲ្យដេកដើរឈរកុំឲ្យខុស ។

ផល្លា៖ លោកពូកាលហ្នឹងមានគ្រួសារនៅ? កាលហ្នឹងការហើយឬនៅ?

ឈួន៖ នៅ!

ផល្លា៖ អត់ទាន់មានទេលោកពូ?

ឈួន៖ បាទ!

ផល្លា៖ អញ្ចឹងដល់ពេល... មេញលោកពូនិយាយខាងសេរីឬក៏ខាងអីគេចូលមកហៅពូទៅធ្វើខាងប៉ាវ៉ា?

ឈួន៖ បាទខាងប៉ាវ៉ា!

ផល្លា៖ ខាងប៉ាវ៉ាហ្នឹងខាងណាវិញលោកពូ?

ឈួន៖ ខាងលោកឯកឧត្តមសឺម សាន្ត!

ផល្លា៖ សឺម សាន្ត?

ឈួន៖ បាទ! ខាងតស៊ូនៅជុំវិញអំពិលយើង!

ផល្លា៖ នៅណាដែរជុំវិញអំពិលហ្នឹង?

ឈួន៖ នៅព្រំដែនថៃ!

ផល្លាៈ ចាំ! ចុះលោកពូថាដំបូងវៀតណាមចូលម៉ោដេញពូ វៀតណាមចូលម៉ោហើយបានខ្មែរក្រហមចូលមកដេញតាមពូ វៀតណាមចូលម៉ោ៧៩?

ឈួនៈ វៀតណាមចូលម៉ោមួយប្រាវចឹងទៅបាត់ជ្រាប វាទៅវិញតែមិនដឹងថាវាទៅទីណាវិញទេ មិនដឹងទៅព្រំដែនឬក៏ទៅណាទេ តែខ្មែរក្រហមវារត់មួយសារហើយវាចូលម៉ោវិញ ។

ផល្លាៈ ខ្មែរក្រហមចូលម៉ោវិញ?

ឈួនៈ បាទ!

ផល្លាៈ វៀតណាមចូលម៉ោនៅឆ្នាំប៉ុន្មានដែរលោកពូ?

ឈួនៈ ឆ្នាំ៧៩!

ផល្លាៈ ឆ្នាំ៧៩ហ្នឹង?

ឈួនៈ បាទ!

ផល្លាៈ ៧មករាហ្នឹងមែនលោកពូ ឬក៏ក្រោយហ្នឹង?

ឈួនៈ ៧មករាឆ្នាំ៧៩ហ្នឹង!

ផល្លាៈ ចាំ! ដល់ពេលទៅបាត់ទៅខ្មែរក្រហមចូលម៉ោវិញ?

ឈួនៈ ខ្មែរក្រហមចូលម៉ោវិញ! តែវាមិនដឹងទៅណាទេមួយសារហ្នឹងព្រោះចេញចូលៗ ។

ផល្លាៈ ខ្មែរក្រហមហ្នឹងចេញចូលៗ?

ឈួនៈ វានៅតែព្រំដែននេះ ខ្មែរក្រហម ។

ផល្លាៈ ខ្មែរក្រហម?

ឈួនៈ បាទ!

ផល្លាៈ អញ្ចឹងបានន័យថាខ្មែរក្រហមចេញចូលទៅម៉ោៗ?

ឈួនៈ បាទ!

ផល្លាៈ ហើយអត់អីទេពូ?

ឈួនៈ នៅចំនុចនោះមូលហេតុដោយសារសារពួកខាងក្នុងនោះមិនទាន់បានដាក់រោងយ័ក្សធ្វើឲ្យអ្នកខាងក្នុងធ្វើការពារឲ្យបានច្បាស់លាស់ទៅដល់នេះវាចេញចូលតាមទំនើងចិត្ត ។

ផល្លាៈ ខ្មែរក្រហម?

ឈួនៈ បាទ! ដល់ក្រោយទៀតខ្មែរខាងក្នុងក៏បានដាក់មេភូមិដាក់សន្តិសុខឲ្យការពារឲ្យបានត្រឹមត្រូវដល់ហើយដេញពួននោះចេញអត់ហ៊ានម៉ោទៀតទេ ។

ផល្លាៈ ដេញខ្មែរក្រហមអត់ឲ្យចូលម៉ោវិញ?

ឈួនៈ ដេញទាំងអស់!

ផល្លាៈ ចុះលោកពូកាលហ្នឹងម៉េចទៅ?

ឈួនៈ ដល់អញ្ចឹងទៅខ្ញុំរត់ទៅនោះទៅ ត្រលប់ម៉ោវិញ..

ផល្លាៈ រត់ទៅណា លោកពូរត់ទៅណា?

ឈួនៈ ទៅជំរុំអំពិល!

ផល្លាៈ ទៅជំរុំអំពិលហ្នឹងតែម្តង?

ឈួនៈ បាទ! ដល់តែទៅជំរុំអំពិលហ្នឹងទៅរយៈពេល៨ខែខ្ញុំត្រលប់ម៉ោវិញ ។

ផល្លាៈ ទៅធ្វើអីខ្លះនៅជំរុំអំពិលហ្នឹង?

ឈួនៈ ធ្វើទាហ៊ាន!

ផល្លាៈ ទាហ៊ាន?

ឈួនៈ បាទ! ទាហ៊ានប៉ារ៉ា!

ផល្លាៈ ទាហ៊ានប៉ារ៉ា?

ឈួនៈ បាទ! ធ្វើទាហ៊ានប៉ារ៉ាការពារប្រទេសថៃ ។

ផល្លាៈ ការពារប្រទេសថៃ?

ឈួនៈ បាទការពារប្រទេសថៃ ហើយមួយចំនួនចុះមកខ្មែរយកពត៏មាន ។

ផល្លាៈ យកពត៏មានហើយម៉េចទៀតទៅ? យកទៅប្រាប់...

ឈួនៈ យកទៅរាយការណ៍ប្រាប់ខាងនោះ ខ្ញុំបានតែប៉ុន្មានខែខ្ញុំចុះម៉ោវិញទៅ ខ្ញុំចុះម៉ោខ្ញុំឈប់តែម្តង

ផល្លាៈ ចុះទាហ៊ានប៉ារ៉ាហ្នឹងអត់មានវ៉ៃអីជាមួយទាហ៊ានខ្មែរក្រហមទេ?

ឈួនៈ វ៉ៃ! ឃើញខ្មែរក្រហមវ៉ៃខ្មែរក្រហម ឃើញយួនវ៉ៃយួន ។

ផល្លាៈ ម៉េចចឹងលោកពូ?

ឈួនៈ វាមិនត្រូវគ្នា! ខ្មែរក្រហមជួបខ្មែរក្រហម វាប្រល័យពូជសាសន៍ វាវ៉ៃបងប្អូនយើងតែឃើញក៏វាវ៉ៃដែរ! ប៉ះយួនអានេះឈ្លានពានដេញពីកម្ពុជាវ៉ៃឲ្យវារត់ទៅវិញ អានោះជួបអាណាក៏ដាក់ៗ ។

ផល្លាៈ ពូវ៉ៃបានច្រើនដែរអញ្ចឹង?

ឈួនៈ បានច្រើន!

ផល្លាៈ បានប៉ុន្មានខែមេញ ៨ខែមែនពូ?

ឈួនៈ ៨ខែ!

ផល្លាៈ ៨ខែហើយបានលោកពូចូលមកភូមិវិញ?

ឈួនៈ បាទ!

ផល្លាៈ ហេតុអីបានចឹងលោកពូ?

ឈួនៈ ខ្ញុំបានប្រពន្ធ!

ផល្លាៈ បានប្រពន្ធពេលណាលោកពូ?

ឈួនៈ បានពេលខ្ញុំរត់ទៅ បានពេល៧៩ហ្នឹង ។

ផល្លាៈ ៧៩! ខ្មែរក្រហមរៀបឲ្យឬក៏ខ្មែរក្រហមរៀបឲ្យលោកពូ?

ឈួនៈ ខ្មែរក្រហមរៀបឲ្យ!

ផល្លាៈ អ៎រៀបឲ្យ?

ឈួនៈ បាទ!

ផល្លាៈ គាត់ឈ្មោះអីដែរលោកពូ គ្រួសារលោកពូ?

ឈួនៈ ទាវ អ៊ុន!

ផល្លាៈ ទាវ អ៊ុន?

ឈួនៈ បាទ!

ផល្លាៈ គាត់ហ្នឹងធ្វើនៅណាដែរលោកពូ? លោកពូស្នើរខ្លួនឯងឬក៏គេរៀបឲ្យ ឬក៏ពូមានស្នើរប្រធានសហករណ៍ថាពេញចិត្តម្នាក់ហ្នឹង?

ឈួនៈ បាទស្នើរ! យើងស័គ្រស្មោះនឹងគ្នាទៅប្រាប់ប្រធានសហករណ៍ទៅ គេប្រមូលអ្នកណាដែលស្រលាញ់គ្នាយកមកពួកដៃគ្នាឲ្យចូលកន្លែងមហាសន្និបាតរៀបអាពាហ៍ពិពាហ៍ ។

ផល្លាៈ នៅណាដែរលោកពូមហាសន្និបាតហ្នឹង?

ឈួនៈ នៅវត្ត!

ផល្លាៈ វត្តណាលោកពូ?

ឈួនៈ វត្តថ្មពួកយើងនេះ!

ផល្លាៈ នៅក្នុងភូមិឃុំ...?

ឈួនៈ ភូមិឃុំថ្មពួកយើងនេះ!

ផល្លាៈ ចា៎! មិនមែនភូមិស្វាយទេ នៅខាងភូមិថ្មពួកនេះវិញ?

ឈួនៈ	បាទនៅភូមិផ្សារអ្នកតា ១០០គូឡើងណែនទោះប៉ុន្តែយប់ហ្នឹងមាននារីម៉ោពីស្រែម៉ោងព,៨ បានគេរៀបការ ។

ផល្លាៈ	គេមានប្រាប់មុនអត់លោកពូពេលថ្ងៃការហ្នឹង?

ឈួនៈ	អាថ្ងៃហ្នឹងគេប្រាប់ពេលល្ងាច គេប្រាប់នៅស្រែនោះឯង!

ផល្លាៈ	ហើយគាត់ហ្នឹងអ្នកនៅណាដែរ នៅកងយុវនារីឬក៏នៅភូមិភាគ?

ឈួនៈ	គ្រួសារខ្ញុំហ្នឹង?

ផល្លាៈ	ចាំ!

ឈួនៈ	នៅកងនារី!

ផល្លាៈ	នៅកងនារី?

ឈួនៈ	បាទ!

ផល្លាៈ	នៅកងនារីជាប្រធានឬក៏ម៉េចដែរលោកពូ?

ឈួនៈ	នៅផ្នែកនារី!

ផល្លាៈ	ផ្នែកនារី? ធម្មតាទេលោកពូអត់មានតួនាទីអីទេណោះ ឬក៏ម៉េចដែរ?

ឈួនៈ	ខ្ញុំអត់សូវដឹងដែរ ជាសមាជិកសមាអីគេខ្ញុំមិនសូវដឹងដែរ!

ផល្លាៈ	ចុះលោកពូអត់មានបានស្នើរគេថាពេញចិត្តគាត់ហ្នឹងដែរទេ?

ឈួនៈ	ស្នើរ!

ផល្លាៈ	ព្រោះក្នុងគូរខ្លះគេអត់មានស្នើរទេលោកពូ! គូរខ្លះគេចាប់គូរឲ្យតែម្តង?

ឈួនៈ	ចាប់បន្ទុំ?

ផល្លាៈ	ចាំ!

ឈួនៈ	បើខ្ញុំនិយាយរួមទៅថាស្នើរក៏បាន ថាម៉ែឪហ្នឹងដូចថាស្រលាញ់ចិត្តគ្នាទៅគេឲ្យកូនហ្នឹងយកគ្នា ។

ផល្លាៈ	ចុះកាលហ្នឹងឪពុកម្តាយលោកពូរស់នៅសហករណ៍មែនលោកពូ ហើយអត់អីណាគ្រួសារលោក ពូ បងប្អូនអី?

ឈួនៈ	មានអី! ឪពុកខ្ញុំនៅតែឪពុកក្មេកខ្ញុំងាប់អស់ហើយ!

ផល្លាៈ	ពូចាំថ្ងៃខែច្បាស់ទេពូ ថ្ងៃខែការថ្ងៃណាពូ?

ឈួនៈ	ឆ្នាំ៧៩!

ផល្លាៈ	៧៩មុនបែកមែនលោកពូ?

ឈួនៈ	អាជិតបែកហ្នឹងអើយ!

ផល្លា៖ មុនបែកឬក៏ការហើយបានបែក៧៩ បែកខ្មែរក្រហម?

ឈួន៖ ការហើយបែក! ការបានមួយខែ!

ផល្លា៖ អ៊ីការហើយបានមួយខែបែក បែកហើយរត់ទៅដីរុំហ្នឹងទៅតែពូឬក៏ប្រពន្ធពូទៅដែរ?

ឈួន៖ កាលមុនខ្ញុំនាំទៅដែរ ដល់ទៅព្រៃគេនៅអត់បានខ្ញុំយកមកវិញ យកមកខ្មែរក្រហមរកខ្ញុំទៅ ខ្ញុំក៏លាក់ប្រពន្ធសិន ។

ផល្លា៖ លាក់នៅណាលោកពូ?

ឈួន៖ លាក់នៅផ្ទះ វេទនាណាស់ប្រពន្ធខ្ញុំ! ដល់ក្រោយមកទៀតគេឈប់រកទៅ ខ្ញុំលាក់ហ្នឹងខ្ញុំរត់ទៅ ទៅតែខ្ញុំ ។

ផល្លា៖ ខ្មែរក្រហមចូលមករកពូប៉ុន្មានដង?

ឈួន៖ មករកនៅនេះពីរដង!

ផល្លា៖ ចាំ! នៅនេះហ្នឹងនៅភូមិនេះ?

ឈួន៖ បាទ!

ផល្លា៖ ហើយម៉េចក៏មិននាំគាត់រត់ដែរលោកពូ លាក់គាត់អញ្ចឹងធ្វើអីរត់ទាំងពីរនាក់ទៅ?

ឈួន៖ ដើមឡើយថាយកទៅដល់វគាត់វតែងពេកក៏យកមកវិញទៅ ដល់យកមកទុកវិញគេរកដល់ពេលរកទៅវាឃើញវាថត ហើយប្រពន្ធខ្ញុំរត់ទៅដល់ឧត្តមានជ័យ ហើយខ្ញុំរត់ទៅថៃ ។

ផល្លា៖ ចាំ! បែកគ្នារត់?

ឈួន៖ បែកគ្នា!

ផល្លា៖ ដល់ហើយម៉េចទៅបានជួបគ្នាវិញ?

ឈួន៖ ហើយជួបគ្នាវិញ!

ផល្លា៖ ពេលណា?

ឈួន៖ ឆ្នាំ៨០ បានជួបគ្នាវិញ ។

ផល្លា៖ ១៩៨០ បានន័យថាចេញពីដីរុំប៉ាវ៉ាវិញហើយ?

ឈួន៖ បាទ!

ផល្លា៖ ម៉េចបានពូចេញពីដីរុំប៉ាវ៉ា គេឲ្យចេញដែរលោកពូ?

ឈួន៖ អត់ទេ! គេមានឲ្យចេញណាខ្ញុំរត់ម៉ោ!

ផល្លា៖ រត់តែម្តងលោកពូ?

ឈួនៈ បាទ! មូលហេតុដែលខ្ញុំរត់គឺនៅប៉ារ៉ាវាដូចជាសាហាវ វាបានកាន់កាំភ្លើងវាអត់ស្គាល់គ្នាទេ អាបងសម្លាប់បងប្អូនឲ្យតែបានធ្វើធំ ខ្ញុំមិនមែនចេះតែនិយាយទេអ្នកតស៊ូទេ គឺខ្ញុំក៏ជាអ្នកតស៊ូដែរដូចបងប្អូនមួយចំនួនបានធ្វើធំហើយអត់ស្គាល់ទេ គឺភ្លេចកំណើត ឧទាហរណ៍ថាកងនេះទៅសម្លាប់កងនោះ អាកងនោះសម្លាប់កងខ្ញុំអាចំនុចនេះហើយដែលខ្ញុំមិនពេញចិត្ត មិនតស៊ូរំដោះ ប្រជាជនាំគ្នាសម្លាប់តែគ្នាឯង បងប្អូនសម្លាប់តែបងប្អូនឯងតស៊ូធ្វើអី? ព្រោះតែបញ្ហានេះ បានខ្ញុំដកខ្លួន ខ្ញុំនឹកឃើញថាបើសិនជាខ្ញុំនៅតស៊ូចេះតែធំដល់ធំទៅអាមនុស្សទាំងអស់ហ្នឹងវា ចេះតែដណ្តើម ដូច្នេះបើយើងនៅវាឡើងមែនស័ក្តយសក៏ប៉ុន្តែយើងត្រូវគេសម្លាប់ ដូច្នេះមិនបានទេបើធំហើយសម្លាប់ដដែលយើងចង់បានធ្វើអី? ដូច្នេះខ្ញុំត្រលប់មកផ្ទះវិញ ។

ផល្លាៈ អញ្ចឹងកាលហ្នឹងពូឡើងដល់ដំណែងអីដែរពេលហ្នឹង?

ឈួនៈ ខ្ញុំគេឲ្យដល់ទៅកងតូចហើយហ្នឹង តែមួយភ្លែតហ្នឹងកងតូចរៀនពេទ្យផងកងតូចទៀត ។

ផល្លាៈ ប្រធានកងសេនាវរៈ?

ឈួនៈ កងតូច!

ផល្លាៈ កងតូចទេ?

ឈួនៈ បាទ!

ផល្លាៈ ប្រធានកងតូច៣០នាក់!

ឈួនៈ ហើយ៣០នាក់ហ្នឹងទៅមានមនុស្សឯណា?

ផល្លាៈ អញ្ចឹងគេមានឲ្យកាន់កាំភ្លើងកាន់អីអត់លោកពូ មានបង្រៀនមានអីទេ?

ឈួនៈ គេបង្រៀនហាត់កាន់យុត្តិសាស្រ្តសង្គ្រាម តែមានកាំភ្លើងពីណាកាលហ្នឹង! កាលហ្នឹងដឹកដំឡូងលក់ ដឹកដំឡូងឲ្យថៅកែបានប្រាក់ម៉ោទិញកាំភ្លើង ។

ផល្លាៈ ទិញកាំភ្លើងពីណាម៉ោលោកពូ?

ឈួនៈ ពីថៃ!

ផល្លាៈ ពីថៃ?

ឈួនៈ បាទ! ទិញពីថៃ ដូរពីថៃ ។

ផល្លាៈ អញ្ចឹងអ្នកគ្រប់គ្រងពីលើពូទៀតឈ្មោះអី អ្នកគ្រប់គ្រងនៅប៉ារ៉ាហ្នឹង ពូធ្វើប្រធានកងតូចហ្នឹងណា៎?

ឈួនៈ ឈ្មោះ ទួន ចាយ!

ផល្លា៖	ទូន ចាយ!

ឈួន៖	មានមុនលោកចាយហ្នឹងទៀត ដល់ក្រោយម៉ោលោកចាយហ្នឹងខ្ញុំរត់ម៉ោនេះ មានម្នាក់ទៀតដែលបងអាព្រុំវាងាប់ វាធ្វើមេប៉ូលីសនៅឧត្តមានជ័យក្រោយម៉ោក៏ងាប់ ពេលចុះម៉ោនេះវាសារភាពដល់សារភាពទៅគេឲ្យធ្វើធំ ដល់ធ្វើធំទៅគាត់ទៅធ្វើនៅឧត្តមានជ័យទៅក៏ងាប់ ។

ផល្លា៖	ងាប់ដោយសារកាលហ្នឹង?

ឈួន៖	មិនដឹងងាប់ដោយសារអី! បើងាប់មានតែងាប់ដោយសាររោគពារគ្មានងាប់ដោយសារអីនោះទេ! ព្រោះទើបតែងាប់ថ្មីៗនេះពីរបីឆ្នាំនេះ ។

ផល្លា៖	អញ្ចឹងពូពេលដែលចុះម៉ោភូមិវិញស្ថានភាពក្នុងភូមិម៉េចដែរ
	ពេលដែលចេញពីប៉ុរ៉ាម៉ោក្នុងភូមិ ហ្នឹងវិញ?

ឈួន៖	អត់មានអីទេព្រោះមេភូមិខាងអី រដ្ឋកម្ពុជាអីទៅអស់ហើយ!

ផល្លា៖	រដ្ឋកម្ពុជាហ្នឹងកាលហ្នឹងមេភូមិឈ្មោះអីគេលោកពូ?

ឈួន៖	តាឆេង!

ផល្លា៖	តាឆេង?

ឈួន៖	តាហាច ស៊ូ ហាច!

ផល្លា៖	ស៊ូ ហាច! ស៊ូ ហាចហ្នឹងមានតួនាទីជាអីដែរលោកពូ?

ឈួន៖	អនុប្រធាន! តាមឹកបានប្រធាន!

ផល្លា៖	ម៉េចបានតាហាចជាប់គុកលោកពូ?

ឈួន៖	ដោយសារកាចោទប្រកាន់មកលើ គាត់ហ្នឹងជាអ្នកគ្រប់គ្រងព្រោះតំបន់នេះជាតំបន់ឆ្លងកាត់របស់ពួកប៉ុរ៉ានិងពួកខ្មែរក្រហម ។

ផល្លា៖	ចាំ!

ឈួន៖	ដល់គេចាប់ទៅគេថាគាត់ចិញ្ចឹមខ្មែរក្រហម ចិញ្ចឹមប៉ុរ៉ាដល់នេះគេចាប់គាត់ដាក់គុក ។

ផល្លា៖	ខាងណាយកទៅដាក់គុកលោកពូ?

ឈួន៖	ខាងរដ្ឋកម្ពុជា!

ផល្លា៖	រដ្ឋកម្ពុជាយកទៅដាក់គុក?

ឈួន៖	បាទ!

ផល្លា៖	អញ្ចឹងតំបូង អក ម៉ុកហ្នឹងជាប្រធាន?

ឈួន៖	អត់ទេ ស៊ូ ហាច!

ផល្លា៖ ស៊ូ ហាចហ្នឹងជាប្រធាន?

ឈួន៖ បាទ!

ផល្លា៖ ដល់ពេល អក ម៉ុក ហ្នឹងជាអនុ?

ឈួន៖ ហ្នឹងអើយ! ដល់ពេលនេះប្រធានជាប់គុកអនុហ្នឹងឡើងវិញ ។

ផល្លា៖ អញ្ចឹងតាមការពិតគាត់មានទាក់ទងជាមួយខ្មែរក្រហមមែនឬអត់លោកពូ បើតាមមើលទៅព្រោះ?

ឈួន៖ តាមពិតចូលមែន!

ផល្លា៖ ចាំ!

ឈួន៖ វាចេញរកអង្ករកអីស៊ីមែន ជំនាន់ហ្នឹងការឆ្លងកាត់របស់ពិរមិត គេថាយើងពិចារមិត ការឆ្លងកាត់បើសិនជាគេខ្វះហើយយើងមិនឲ្យវាមិនកើត ដូច្នេះត្រូវតែឲ្យ ហើយដល់ពេលគេរៃអង្គាសមួយកំប៉ុងពីកំប៉ុងគេបានទៅគេចេញទៅ ។

ផល្លា៖ ខ្មែរក្រហមចូលមករៃអង្គាសមែនលោកពូ?

ឈួន៖ បាទ!

ផល្លា៖ មានកាំភ្លើងមានអីអត់លោកពូ?

ឈួន៖ មាន!

ផល្លា៖ ចុះយើងមានទាហ៊ានយើងដែរលោកពូ ការពារអត់កើត?

ឈួន៖ ទាហ៊ានអត់មានទេ! វានៅតែកន្លែងស្រុកហ្នឹង!

ផល្លា៖ លោកពូពេលដែលលោកពូចេញពីប៉ាវ៉ៃមកនៅនេះមានតួនាទីអីដែរ?

ឈួន៖ ខ្ញុំធ្វើមេក្រុម!

ផល្លា៖ ធ្វើមេក្រុម?

ឈួន៖ បាទ!

ផល្លា៖ មេក្រុមនៅក្នុងភូមិមែនលោកពូ?

ឈួន៖ បាទ!

ផល្លា៖ មេក្រុមហ្នឹងមេក្រុមនៅក្នុងភូមិស្វាយហ្នឹងឬមែនទេ?

ឈួន៖ បាទ! មេក្រុមហ្នឹងគ្រាន់តែកាន់១០គ្រួសារ ។

ផល្លា៖ កាន់តែ១០គ្រួសារទេ ហើយម៉េចទៀតលោកពូ? ម៉េចបានគេឲ្យដំណែងអញ្ចឹងលោកពូ?

ឈួន៖ មេភូមិគេរើស!

ផល្លា: គេរើស?

ឈួនៈ បាទ! ក្រោយពីនៅត្រឹម៨២ម៉ោកើតជាមេក្រុម ៨២,៨៣ទៅកាន់នៅមេ៩០ខ្ទង់ទៀត ។

ផល្លា: លោកពូឡើងទៅមេ៩០ខ្ទង់វិញទៀត?

ឈួនៈ បាទ! ក្រោយពី៩០ខ្ទង់ហ្នឹងទៅដល់នគរបាលទៀត ។

ផល្លា: ចាំ! អញ្ចឹងពេលដែលគ្រប់គ្រងហ្នឹងខ្មែរក្រហមមានអីទៀតអត់លោកពូ ពេលដែលពូឡើងធ្វើ ៩០ខ្ទង់អីចឹងណាំ?

ឈួនៈ វាម៉ោម្តង១ វាមកសុំអង្ករសុំអីហ្នឹង ដូច្នេះវាមានពីរមានខ្មែរក្រហមមានប៉ារ៉ា តែវាចូលម៉ោដឹងតែសុំអង្កហើយ ពេលសុំអង្កហើយត្រូវតែរាយការណ៍ទៅរដ្ឋកម្ពុជាគេរករឿងយើងថា យើងហ្នឹងមិនផ្តល់ព័ត៌មានឲ្យគេ ដូច្នេះពេលដែលវាចេញហើយបានផ្តល់ព័ត៌មានឲ្យគេ ដូច្នេះ បញ្ហានៅក្នុងភូមិជួបការលំបាកណាស់ លំបាកត្រង់ថាបើសិនធ្វើអីមួយបើមិនប្រាប់គេគឺត្រូវ គ្រោះថ្នាក់យើង ដូច្នេះបើសិនជាពួកខ្មែរក្រហមក៏ដោយប៉ារ៉ាក៏ដោយមករែអង្កក៏ត្រូវតែប្រាប់ គេ ។

ផល្លា: អញ្ចឹងខាងប៉ារ៉ាហ្នឹងមានរែអង្ករដែរលោកពូ?

ឈួនៈ រែដូចគ្នា!

ផល្លា: អញ្ចឹងពូថាកាលជំនាន់ហ្នឹងខ្មែរក្រហម ពេលដែលបែក៧៩ខ្មែរក្រហមនៅធ្វើឃោសនាធ្វើឲ្យ ប្រជាជនទុកចិត្តហ្នឹងយុទ្ធសាស្ត្រគេយ៉ាងម៉េចទៅលោកពូ?

ឈួនៈ យុទ្ធសាស្ត្រវាថាមិនលួចមិនប្លន់ចេះជួយអ្នកស្រុកត្រង់ថា គេឲ្យហៅគេទឹកជាតិគេមិនឲ្យហៅ គេថាខ្មែរក្រហមទេ ហើយគេថាបើសិនជាបងប្អូនធ្វើស្រែនៅកន្លែងណាគេនៅការពារយើង ក៏ប៉ុន្តែឲ្យយើងហ្នឹងចែកអង្ករឲ្យគេស៊ីផង! ឬក៏បងប្អូនខ្វះគោប្រើអីគេជួយ ដល់ជូនទៅវិញទៅ គេសុំថ្ងៃដំណើរថ្ងៃអីទៅតាមដំណើរសុវត្ថិភាពអត់មានអីទេ អាដូវចិត្តសាស្ត្រដែលវាធ្វើហ្នឹង ល្អរបស់វាមែន ។

ផល្លា: ចាំ!

ឈួនៈ ក្រោយម៉ោទៀតវាហៅ វានៅតាមបុកហ្នឹងដូចនៅតាមបុកត្រាចហ្នឹង ហើយនៅតំបន់វាអត់ មានលួចអត់មានប្លន់ទេ នៅតំបន់ខ្វះដែលមានប៉ារ៉ាមានលួចគោមានលួចអី ដូច្នេះសុវត្ថិភាព ប៉ារ៉ានិងខ្មែរក្រហមគឺខុសគ្នា គឺខ្មែរក្រហមវាសុវត្ថិភាពអត់មានចោរទេ ហើយក្រោយម៉ោទៀត បានប៉ារ៉ាកំទេចចោលអត់ឲ្យមានទេដេញទាំងអស់អត់ឲ្យមានទេ ។

ផល្លា: ពីណាគេអ្នកដេញពូ?

ឈួនៈ	ប៉ាវ៉ា!

ផល្លាៈ	ខ្មែរក្រហមដេញប៉ាវ៉ាឬក៏ទ័ពកម្ពុជាដេញ?

ឈួនៈ	ប៉ាវ៉ាហ្នឹងដេញខ្មែរក្រហម ។

ផល្លាៈ	ដេញខ្មែរក្រហមវិញ?

ឈួនៈ	ដេញខ្មែរក្រហមមួយសារ ដល់ក្រោយម៉ោទៀតរដ្ឋកម្ពុជារលាយទាំងអស់ ។

ផល្លាៈ	រលាយម៉េចទៅលោកពូ?

ឈួនៈ	រលាយពួកប៉ាវ៉ា រលាយពួកនេះ!

ផល្លាៈ	នៅឆ្នាំប៉ុន្មានលោកពូ?

ឈួនៈ	មិនដឹងប៉ុន្មានទេភ្លេចបាត់ហើយ!

ផល្លាៈ	អញ្ចឹងក្នុងភូមិហ្នឹងម៉េចដែរពេលដែលគេដាក់សមាវ័ន្តកម្មចូលនៅត្រីភាគីណា៎លោកពូ?

ឈួនៈ	នៅត្រីភាគីមានតំបន់ខ្លះគឺមានការលួចគោ លួចក្របី គឺវេទនាខ្លាំងណាស់ ។

ផល្លាៈ	ពីណាអ្នកលួចលោកពូ?

ឈួនៈ	រកមុខវាមិនឃើញ! ខ្មែរក្រហមក៏មានប៉ាវ៉ាក៏មានដល់ចឹងទៅមិនដឹងអ្នកណាជាអ្នកលួច ។

ផល្លាៈ	លោកពូមានស្គាល់មេដឹកនាំខ្មែរក្រហមអីធំៗទេលោកពូ?

ឈួនៈ	ស្គាល់! ប៉ុន្តែគេមិនដែលប្រាប់ថាកូនចៅគេលួចទេ! ខ្មែរក្រហមធំៗមិនដឹងទៅណាអស់ព្រុតែឈ្មោះ ។

ផល្លាៈ	ពីណាខ្លះពូ?

ឈួនៈ	ដែលស្គាល់នោះព្រុតែឈ្មោះទេ!

ផល្លាៈ	ដូចយាយថែមអីលោកពូដែលស្គាល់គាត់ទេ?

ឈួនៈ	យាយថែម?

ផល្លាៈ	ចា៎! អឹម ថែម?

ឈួនៈ	ព្រុតែឈ្មោះតែមិនដឹងនៅណាទេ?

ផល្លាៈ	អឹម ថែមហ្នឹងគាត់ប្រធាននៅត្រពាំងថ្មហ្នឹង ។

ឈួនៈ	ស្គាល់តែឈ្មោះតែមិនដែលឃើញមុខទេ! មានតែយាយថែមហ្នឹងហើយនឹងឈ្មោះស្តី ហ៊ាន ព្រុតែឈ្មោះពីនាក់ហ្នឹងតែមិនដឹងមុខមាត់យ៉ាងម៉េច ដែលស្គាល់នោះស្គាល់តែតួចគាចដែលមកសុំអង្ករនោះ ហើយមនុស្សយាមក្បែៗដែលយើងធ្វើស្រែនោះគឺស្គាល់ ។

ផល្លាៈ	ចុះអៀង សារី, នួន ជាអីអត់ដែលឃើញទេលោកពូ?

ឈួនៈ មិនដែលឃើញទេ!

ផល្លាៈ ចុះលោកពូស្គាល់ ហុង ពិន ទេ?

ឈួនៈ មិនដែលស្គាល់ផង!

ផល្លាៈ គាពិនព្មថាគាត់ធ្លាប់ដូរមករៀននៅស្វាយចេក គាត់មកបង្រៀននៅស្វាយចេក ។

ឈួនៈ គាត់នៅស្រុកស្វាយចេក តែមិនដឹងមុខមាត់គាត់យ៉ាងម៉េច!

ផល្លាៈ អញ្ចឹងពូអត់ដែលឃើញគាត់ អត់ដែលស្គាល់គាត់ទេ?

ឈួនៈ អត់!

ផល្លាៈ អត់មានដឹងពត៏មានអីសោះលោកពូ?

ឈួនៈ អត់ទេ!

ផល្លាៈ ចុះព្មថាមានចោចូលបូន់សម្លាប់ប្រពន្ធគាត់អីហ្នឹងពូអត់ដឹងទេ?

ឈួនៈ អត់!

ផល្លាៈ ចុះលោកពូនៅហ្នឹងតំបូងនៅក្នុងខេត្តបាត់ដំបងមែនទេលោកពូ អត់ទាន់..!

ឈួនៈ បាទ! ខេត្តបាត់ដំបង!

ផល្លាៈ ចុះគេបំបែកមកបន្ទាយមានជ័យនៅឆ្នាំណាដែរលោកពូ?

ឈួនៈ ឆ្នាំ៨៦!

ផល្លាៈ ៨៦បានបែក?

ឈួនៈ បាទ! ៨៦បានបែក ។

ផល្លាៈ បំបែកខេត្តហ្នឹងដោយសារអីលោកពូ?

ឈួនៈ ខេត្តធំពេក!

ផល្លាៈ ខេត្តធំពេកបានបំបែក! តែប៉ុណ្ណឹងទេលោកពូណោះ?

ឈួនៈ បាទ!

ផល្លាៈ ហើយនៅខេត្តបន្ទាយមានជ័យហ្នឹងទាំងអស់ហ្នឹងពូមានដឹងថាមានភូមិឃុំអីខ្លះទេ ស្រុកអីទាំងអស់ប៉ុន្មានចឹងណា៎?

ឈួនៈ មាន៨ស្រុក!

ផល្លាៈ ចុះប្រជាជននៅហ្នឹងភាគច្រើនគេរកស៊ីអីលោកពូ?

ឈួនៈ ច្រើនតែកសិករ ខ្ញុំមិនសូវដឹងអារឿងខាងស្រុកគេទេ!

ផល្លាៈ ចា៎! បើនៅភូមិនេះម៉េចដែរអញ្ចឹង?

ឈ្នួនៈ នៅនេះធ្វើតែស្រែទេ!

ផល្លាៈ ហើយនៅនេះអត់មានពីណានិយាយភាសាថៃអីទេលោកពូ ខ្ញុំឃើញនៅនេះភាគច្រើនចាយលុយចាយអីគិតជាបាតណា៎លោកពូ?

ឈ្នួនៈ សព្វថ្ងៃច្រើនចាយលុយខ្មែរវិញហើយ! វាចំរុះគ្នាខ្មែរហើយនឹងថៃ តែថៃតិចជាងខ្មែរដោយសារថាប្រាក់ខ្មែរ ឧទាហរណ៍ថាដូរមួយរយអញ្ចឹងទៅអាប្រាក់ខ្មែរហ្នឹងវាច្រើន ។

ផល្លាៈ ចា៎!

ឈ្នួនៈ ហើយបញ្ហាលុយដែលប្រជាជនបានលុយបាតដោយសារថាលក់ស្រូវទេ ហើយក្រៅពីស្រូវអត់បានលុយទេ លក់ជ្រូកលក់មាន់លក់ទាគឺបានតែលុយខ្មែរទេ ។

ផល្លាៈ អ៎! លក់ស្រូវលក់ទៅឲ្យថៃ?

ឈ្នួនៈ លក់ឲ្យឈ្មួញហ្នឹងឯងតែគេឲ្យលុយបាត ។

ផល្លាៈ ឈ្មួញហ្នឹងជនជាតិថៃឬក៏ខ្មែរ?

ឈ្នួនៈ ខ្មែរតែគេទិញយកទៅលក់ឲ្យថៃ វៀតណាមមកទិញដល់នេះ វាគិតប្រាក់ដុល្លាក៏គិតប្រាក់ថៃក៏បាន ។

ផល្លាៈ ឆ្នាំហ្នឹងលក់ដាច់ទេពូស្រូវ?

ឈ្នួនៈ លក់ដាច់! ប៉ុន្តែនៅតែ៩!

ផល្លាៈ ៩ហ្នឹងអីគេ? អង្ករឬស្រូវ?

ឈ្នួនៈ ស្រូវម៉ាលីយើង! កាលពីមុនស៊ីន១០ឥលូវចុះម៉ោ៩ ។

ផល្លាៈ ៩រយឬក៏៩បាត?

ឈ្នួនៈ ៩បាត!

ផល្លាៈ ៩បាតមួយពាន់ជាងលុយខ្មែរហើយ?

ឈ្នួនៈ បាទមួយគីឡូ!

ផល្លាៈ ចា៎! ចុះពូថាឆ្នាំហ្នឹងពេលអុំទូកមានលិចទឹកមានអីខាងមង្គលបូរីណា៎លោកពូ មានឬអត់?

ឈ្នួនៈ លិចៗ!

ផល្លាៈ លិចហ្នឹងដោយសារអីលោកពូ?

ឈ្នួនៈ លិចស្រូវ?

ផល្លាៈ គេថាមានលិចទឹកលិចអី?

ឈ្នួនៈ បាទដោយសារទឹកច្រើនបានលិច!

ផល្លា៖	ម៉េចបានលិចអញ្ចឹងលោកតូ? ខ្ញុំឃើញទឹកទន្លេអីដូចអត់មានឡើងខ្លាំងផងហ្នឹង?

ឈួន៖	ទឹកម៉ោពីថៃច្រើន!

ផល្លា៖	ទឹកម៉ោពីថៃ?

ឈួន៖	បាទ!

ផល្លា៖	ម៉េចបានអញ្ចឹងថៃវាទម្លាក់មែនលោកតូ?

ឈួន៖	ភ្លៀងខ្លាំងពេលនៅនោះ!

ផល្លា៖	លិចប៉ុន្មានថ្ងៃលោកតូ?

ឈួន៖	លិចប្រហែលជាមួយអាទិត្យ ឬក៏មួយខែឯណោះ លិចឡើងដាច់ទំនប់អស់!

ផល្លា៖	ទំនប់ហ្នឹងម៉េចបានដាច់ ភ្លៀងខ្លាំងពេក?

ឈួន៖	បាទខ្លាំង!

ផល្លា៖	ទន្លេនៅខាងណាលោកតូ?

ឈួន៖	អត់មានទន្លេទេ! មានតែទំនប់ធារាសាស្រ្ត ។

ផល្លា៖	ទំនប់ទឹកហ្នឹងទំនប់យើងធ្វើខ្លួនឯងឬក៏តាំងពីជំនាន់ណាលោកតូ?

ឈួន៖	ទំនប់ពីដើមយូហើយ ប៉ុន្តែយើងធ្វើថែមក្រោយទៀត ។

ផល្លា៖	អញ្ចឹងទំនប់ហ្នឹងឈ្មោះអីគេដែរទំនប់ហ្នឹង ទំនប់ដែលថាដាច់ទំនប់ហ្នឹងឈ្មោះអីគេ គេអត់មានឈ្មោះទេ?

ឈួន៖	គេហៅតែទំនប់ៗ!

ផល្លា៖	ហៅទំនប់ធម្មតា?

ឈួន៖	បាទ!

ផល្លា៖	លិចប៉ុន្មានថ្ងៃលោកតូ?

ឈួន៖	កន្លះខែ!

ផល្លា៖	ហើយយើងរស់នៅយ៉ាងម៉េចទៅលោកតូ លុយទឹកលុយអីអញ្ចឹងទៅ?

ឈួន៖	លុយ! ខ្ញុំតាំងពីសក់ខ្មៅដល់សក់សអត់ដែលពុកទេទើបតែពុកនេះឯង!

ផល្លា៖	ខ្ញុំអត់ដែលពុកដែរ!

ឈួន៖	ទើបតែលិចឆ្នាំហ្នឹងឯង!

ផល្លា៖	អញ្ចឹងខូចស្រូវអីដែរអត់ទេលោកតូ?

ឈួន៖	ខូច៥០ភាគរយ!

ផល្លា៖ អុំ!៥០ភាគរយ!

ឈួន៖ ដូចថាទឹកវាចូលដល់អញ្ចឹងវាអត់មានដាក់គ្រាប់ ។

ផល្លា៖ ចុះអត់មានជម្ងឺមានអីទេលោកពូ លិចទឹកអញ្ចឹងក្រែងលោវាអាចឆ្លងជម្ងឺឆ្លងអីចឹង?

ឈួន៖ មានតើជម្ងឺ តែមានតិចតួច ។

ផល្លា៖ អញ្ចឹងលិចហ្នឹងលិចភូមិណាខ្លះ មណ្ឌលបូរីអីនៅនេះលិចដែរ?

ឈួន៖ គ្រប់ភូមិ!

ផល្លា៖ គ្រប់ភូមិ?

ឈួន៖ លិចគ្រប់តែភូមិហ្នឹង! ឡូតែខេត្តបន្ទាយមានជ័យនេះទូទៅតែម្ដង!

ផល្លា៖ អញ្ចឹងទើបតែស្រកដែរទឹកហ្នឹង?

ឈួន៖ បាទ!

ផល្លា៖ ពូមានអីចង់បន្ថែមទៀតទេទាក់ទងនឹងរបបហ្នឹង ជីវិតពេលនៅធ្វើប៉ុវ៉ាអីហ្នឹងមានអីចង់បន្ថែមទៀតទេ?

ឈួន៖ មានអីបន្ថែមធ្វើតែបន្តិចរត់ម៉ោវិញហ្នឹង! គ្រាន់តែថាវាមិនស៊ីចន្ទាក់គ្នាក្នុងការតស៊ូ ។

ផល្លា៖ ចុះលោកពូមានកូនប៉ុន្មាននាក់ដែរ?

ឈួន៖ ៥នាក់!

«ចប់»